# ជំរាបអ្នកអាន

ប្រលោមលោក រឿងប្រាក់ប្រាំដុល្លារ ដែលលោកអ្នកកាន់បំណាងបើកផ្ទាត់ទំព័រអាននេះ បាននិពន្ធរួចកាលពីឆ្នាំ២០០៣ ហើយបំណងថតជាខ្សែ VIDEOប៉ុន្តែដោយគ្មានឱកាសនិងលទ្ធភាព ទើបសម្រេចចិត្តផ្ដល់សិទ្ធិជូនបណ្ណាគារ បោះពុម្ពជាសៀវភៅសិន ។

រឿងនេះជាគតិរំឭកស្មារតីដល់បងប្អូនទាំងអស់ ទោះក្នុងប្រទេសនិងក្រៅប្រទេស ដែលមានបំណងជួយសង្គ្រោះបងប្អូនក្រុមគ្រួសារ ឱ្យពិនិត្យពិចារណាដោយផ្ទាល់ផង ។

ហើយក៏តម្រូវទៅតាមកាលៈទេសៈស្រុកទេសទើបងើបពីសង្គ្រាមបែកបាក់គ្នា ខ្លះនិរាសភៀសខ្លួនទៅដល់ប្រទេសទីបី ពាសពេញពិភពលោក ខំកសាងជីវិតថ្មី សន្សំបានទ្រព្យសម្បត្តិតាមលទ្ធភាព ទីបំផុតងាកមកស្វែងរកក្រុមគ្រួសារញាតិមិត្ត ដែលមានជីវិតរស់នៅក្នុងស្រុក ហើយបានជួយឧបត្ថម្ភជ្រោមជ្រែងឱ្យរស់មានជីវភាពសមតាមឋានៈ ។

ប៉ុន្តែទ្រព្យសម្បត្តិជាថវិកាទាំងនោះ ក៏ជាគ្រឿងប្រហារឬថ្នាំពិសសម្លាប់អ្នកជាក្រុមញាតិ ដែលរស់ក្នុងសង្គមពុំទាន់មានស្ថេរភាព ផ្នែកសីលធម៌និងគុណធម៌នោះដែរ ។

ម្យ៉ាងទៀតអ្នកនិពន្ធសូមអភ័យទោស ចំពោះលោកអ្នកប្រាជ្ញកវី

បណ្ឌិតទាំងឡាយ ពិសេសលោកអ្នកអាន បើឃើញមានការឆ្គាំឆ្គង ក៏មេត្តាអនុគ្រោះ ព្រោះពាក្យពេចន៍សំដីតម្រូវន័យតាមភាសាអ្នកស្រុក អ្នកតំបន់ពីដើម ហើយបច្ចុប្បន្នត្រូវលាយចម្រុះអ្នកចំណូលថ្មីភាគច្រើន ឯអក្ខរាវិរុទ្ធ គឺប្រើតាមខេមរៈយានកម្មវចនានុក្រម សម្ដេចព្រះសង្ឃរាជ **ជួន ណាត** ក្នុងទសវត្សរ៍ ៦០ ។

ភូមិបេង ឃុំអន្លង់វិល ស្រុកសង្កែ

ខេត្តបាត់ដំបង

ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៥





# រឿង ធ្លាក់ជើងល្ពាង

## វគ្គទី១

## គ្រោះដាំបបរ

រាត្រីវនោចអាកាសត្រជាក់, សន្សើមធ្លាក់ដក់ជាមជោគអស់ទាំងរុក្ខជាតិ ។ លើវេហាស៍តារារាប់លានដួងកំពុងបញ្ចេញពន្លឺតាមអនុភាពរៀងខ្លួនបំភ្លឺរាត្រីដែលគ្មានដួងព្រះចន្ទរះ ។ តាមផ្ទះនិមួយៗ មនុស្សម្នាកំពុងនិទ្រាលង់លក់យ៉ាងស្កប់ស្កល់ ឮសូរតែសំឡេងដង្ហើមដកចេញចូលទៅតាមចង្វាក់ចលនាបេះដូងនឹងសួត ។

ជុំវិញផ្ទះឮតែសំឡេងសត្វចង្រិតស្រែកយំរងំកំដររាត្រីស្ងាត់ រហូតចូលដល់យាមបីមាន់មមើរងាវម្ដងៗ។ មិនយូរប៉ុន្មាន,សម្លេងនេះឆ្លើយឆ្លងគ្នាពីផ្ទះមួយទៅផ្ទះមួយទ្រហឹងពេញភូមិ គឺជានិយាមកាលសម្រាប់ដាស់អ្នកស្រុក ដែលលោកតែងតែពោលថាមាន់រងាវកុះ ។

នៅគេហដ្ឋានតូចមួយក្នុងភូមិបេង ខាងជើងទីប្រជុំជនផ្សារស្រុកសង្កែខេត្តបាត់ដំបង យើងឃើញយុវជនម្នាក់សម្បុរជ្រះ,មុខមូលពងក្រពើច្រមុះស្រួចបន្តិច,សក់រួចអង្គាជី,រាងស្ដើង ។

កំពុងអង្គុយសំកុករុញអុសនៅមុខចង្ក្រានដាំបបរមួយឆ្នាំងធំតែម្នាក់ឯង។ យូរៗគេក្រោកឈរពត់ខ្លួន ហើយងាកមើលទៅផ្ទៃមេឃឯទិសបូព៌ា រួចចេញទៅលុបលាងមុខមាត់,ទើបចាប់សៀវភៅមកអាននៅក្បែរពន្លឺភ្លើងទៀនជិតចង្ក្រាននោះ ។ តែគេឧស្សាហ៍ចាប់វែកធំមួយមកកូរពិនិត្យមើលគ្រាប់អង្ករ ដែលកំពុងកញ្ជ្រោលតាមកំសួលទឹកពុះក្នុងឆ្នាំង។ យុវជនរូបនោះគឺឈ្មោះ**សេក** ជាប្អូនបង្កើតរបស់នាងសៀក ត្រូវជាប្រពន្ធរបស់**ចិម** ដែលមានកូនប្រុសពីរនាក់នៅក្នុងបន្ទុកគឺ**ចននិងចឹម** ។ សេកនិងសៀកមានឪពុកម្ដាយនិងបងប្អូនជាច្រើននាក់ទៀត តែត្រូវស្លាប់អស់ក្នុងកំឡុងសង្គមដ៍ខ្មៅងងិត។ គ្រួសារនេះ,នៅសល់តែបងស្រីច្បងបង្អស់ម្នាក់ឈ្មោះ**សោម**ត្រូវបែកទៅនៅឯប្រទេសទីបីគឺសហរដ្ឋអាមេរិក ប៉ុន្តែគេពុំបានដឹងថាមានបងប្អូននៅរស់ម្នាក់ ហើយខ្ចាត់ព្រាត់ទៅដល់ ឯនាយសមុទ្របែបនេះទេ លុះក្រោយមកទើបឮដំណឹង តែមិនច្បាស់លាស់។

សេកត្រូវរស់នៅជាមួយសៀក រកស៊ីពីរនាក់បងស្រីតាមមធ្យោបាយ បានដូចលលកញីឈ្មោលរហូតនាងសៀកមានប្ដីមានកូន ទើបគេចូលរៀនសាលា ។

គេតែងជួយធ្វើការផ្ទះសព្វយ៉ាងទើបចេញទៅរៀន ពេលនេះគេកំពុងដាំបបរឱ្យនាងសៀកលក់ដូចសព្វដង។ កាលបើដឹងថាអង្កររីកហើយ





គេទុកសៀវភៅក្រោកឈរពត់ខ្លួនបំបាត់ការរោយស្រពន់បន្តិច,ទើបបន្ថយភ្លើងស្រែកហៅស្ត្រីម្នាក់ ដោយសម្លេងសុភាពៈ"ចែអើយ.!អង្ករីកហើយចែមកមើលមើល៍ល្មមបង់គ្រឿងឬនៅ?"។ ស្ត្រីដែលគេស្រែកហៅនោះគឺជានាងសៀកបងស្រីរបស់សេក, នាងសៀកដែលកំពុងនិន្ទ្រានៅឡើយក៏ភ្ញាក់ដឹងខ្លួនឡើង ហើយប្រាប់ទៅវិញៈ "អើ.!បន្ថយភ្លើង..ហើយស្រង់ត្រីមកបេះផង..អញចុះទៅឥឡូវហើយ!" ។

នាងសៀកមានកូនពីរនាក់កំពុងតែរៀនសាលា ឯប្ដីជាអ្នករត់ការហៅម៉ូយតាក់ស៊ីនៅបេនឡានផ្សារថ្មីបាត់ដំបង ។ គ្រួសារនេះមានសភាពរស់នៅត្រដាបត្រដួសបន្តិច ទើបសេកជួយរកស៊ីផងនិងរៀនផង ។

ថ្ងៃរះព្រាងៗសេករែកបបរជាមួយក្មួយចនជាកូនច្បងរបស់សៀកមកដាក់រានផ្សារ ជួយរៀបចំកន្លែងលក់ដូរជូនបងស្រី ទើបប្រញាប់មករៀបចំខ្លួនស្លៀកពាក់ទៅរៀន ។ ថ្ងៃនេះមុននិងស្ពាយសំពៀតចេញទៅសាលា សេកបើកឆ្នាំងស្រស់ស្រូបបាយកកបន្តិច តែត្រូវក្មួយចឹមជាកូនពៅនាងសៀកឃើញ ហើយដើរមកពិនិត្យៈ"ពូសេកៗ.!ស៊ីបាយកកកុំយកត្រីអាំងម៉ែនៅលើកញ្ច្រែងណា៎!" ។

ចឹមជាក្មេងច្រឡឹមហើយមិនចេះគោរពកោតក្រែងសេកទេ ព្រោះតែនាងសៀកជាម្ដាយស្រឡាញ់និងអនុគ្រោះកូនខ្លាំងពេក។ក្នុងផ្ទះនេះក្រៅ

ពីលោកចិមជាឪពុកចេញ ចឹមគ្មានញញើតនរណាទាំងអស់ ។

សេកកំពុងតែឆីក៏ងាកមកប្រាប់ ហើយហៅក្មួយចឹមឱ្យចូលមកឆីជាមួយ,"ទេ..ទេ! ពូញាំុជាមួយឆ្អឹងត្រីទេតើ!" ។

ព្ញដូច្នេះ ចឹមដើរមកជិតឃើញក្បាលត្រី ដែលម្តាយស្ងោរធ្វើបបរ ហើយសេកកំពុងឆី:"អឺ.! ពូឯងខូចណាស់! ម៉ែឱ្យបេះត្រីដាក់បបរ ធ្វើឱ្យសល់សាច់ជាប់និងឆ្អឹងច្រើនៗទុកស៊ីខ្លួនឯង..ចាំមើលណា៎!" ។ សេកមិនសូវជាចាប់អារម្មណ៍និងសំដីក្មួយចឹមរបស់គេនេះទេ ព្រោះបានយល់ចរិតក្មេងនេះរហូតឈប់ប្រកាន់ទៅហើយ:"ចាំមើលអីក្មួយចឹម បើឃ្លានមកញាំុជាមួយពូ!" ។

ចឹមជាកុមាររបិលរប៉ូចបំផុតក្នុងផ្ទះនេះ វាចេះនាំពាក្យអុជអាលពីល្អទៅអាក្រក់និងពីអាក្រក់ទៅជាល្អបាន តែសេកមិនប្រកាន់គិតតែពីស្រស់ស្រូបចម្អែតក្រពះប្រញាប់ទៅរៀន ។

កាលបើដឹងថាសេកហៅ ដោយគ្មានលាក់លៀមដូច្នេះ វាបែរជាឆ្លើយដោយមិនចាប់អារម្មណ៍ទៅវិញ:"ខ្ញុំមិនឃ្លានទេ ចាំសុំលុយម៉ែទិញនំវិញ"។ ពោលរួចក៏ចេញលុបលាងមុខមាត់ រត់ទៅផ្សារសុំលុយម្តាយបាត់ទៅ,ឯសេកក៏ស្រូតដំណើរធ្វើរជើងឆ្ពោះទៅសាលាដែរ។គេជាសិស្សរៀនថ្នាក់ទី៨នៃអនុវិទ្យាល័យអន្លង់វិលស្រុកសង្កែ យុវជនរូបនេះខំរៀនណាស់





ដែរ តែពេលវេលាកិច្ចការផ្ទះតម្រូវឱ្យគេច្រើនពេក ម្ល៉ោះហើយចំណាត់ថ្នាក់បានត្រឹមតែមធ្យមឬក្រោមមធ្យមស្ទើរតែរាល់ខែ ។

* * *

សេកជាយុវជនស្លូតបូតសុភាពរាបសា ទាំងសំដីនិងកាយវិការ ហើយជាមនុស្សចេះគោរពចាស់ទុំញាតិជិតខាងនិងមានចិត្តចេះកោតក្រែងអ្នកក្នុងផ្ទះនេះជាខ្លាំង។ ក្នុងចិត្តគេពោរពេញទៅដោយក្តីអាណិតបងស្រីដែលខំស៊ូប្រកបរបរលក់បបរចិញ្ចឹមគ្រួសារ, ឯចិមជាបងថ្លៃវិញព្រឹកចេញព្រលប់ចូល តែពុំសូវបានលុយផ្គត់ផ្គង់គ្រួសារប៉ុន្មានទេ ហើយមកដល់ផ្ទះវិញមានសភាពទ្រេតទ្រោត ព្រោះតែស្រវឹងមានស្ទើរតែរាល់ថ្ងៃ។ ពេលស្រវឹងម្តងៗ តែងតែនិយាយដៀមដាមទ្រគោះបោះបោក ដាក់សេកជានិច្ចទង្វើរបស់បងថ្លៃនេះ បើសិនជានាងសៀកមានចិត្តគំនិតគាំទ្រដែរ ប្រហែលជាសេកពុំហ៊ានរស់នៅជាមួយបានឡើយ ។

រសៀលនេះ សេកបានទំនេរពីការសិក្សា គេនៅផ្ទះខំពុះអុសបំបែកទុកសម្រាប់ឡើងដណ្តាំបបរនៅពេលយប់ទៀតភ្លឺ ។

កំពុងតែធ្វើការក៏ត្រូវបងស្រីហៅ:"សេកអ្ហើយសេក! ម៉េចហើយនៅ?"។សេកដៃម្ខាងកាន់អុសដៃម្ខាងកាន់ពូថៅពុះផងឆ្លើយផង:"បាទជិត

រួចហើយ! មានការអីឬចែ?" ។

-អើ! អញ្ជើញមកនេះសិនមើលអញត្រូវការប្រើបន្តិច!,នាងសៀកពោល។ សេកដាក់ពូថៅចុះ ស្រាយកន្សែងពីចង្កេះមកជូតញើស ហើយដើរទៅជួបបងស្រី:

-ម៉េចចែមានការអីដែរ ?,

សៀកអើតមើលទៅគំនរអុសខាងក្រោមបន្តិច ហើយលូកទាញកន្ត្រកលុយមករាប់ឱ្យសេក :

-អើ! បើពុះអុសអស់ហើយ ប្អូនយកលុយនេះទៅទិញត្រី ទិញគ្រឿងបបរមកទុកមួយភ្លែត អញដូចជាពុំសូវស្រួលខ្លួនសោះ! .

សេកទទួលយកលុយ ហើយនិយាយរំឭកបងស្រី:

-បើចែមិនស្រួលខ្លួនគួរសម្រាកឱ្យបានច្រើនបន្តិចទើបបានណា៎!,

គេទាញអាវមកពាក់ ហើយទៅយកកន្ត្រកដាក់ឥវ៉ាន់ ដើរចេញទៅ ។ ការយួរកន្ត្រកឡើងផ្សារបែបនេះ គេធ្លាប់ធ្វើជាញឹកញាប់ណាស់មកហើយ ដំបូងហាក់អៀនខ្មាស់អ្នកផ្សារដែរ លុះយូរទៅក៏ធ្លាប់ដូចគេឯងដែរ ។





# ចេញមកផ្ទះប្រទះកង់ខូច

ថ្ងៃនេះកម្មវិធីសិក្សា ត្រូវចប់នៅម៉ោង៩:៣០នាទីព្រឹក,សេកប្រញាប់ប្រញាល់ត្រឡប់មកផ្ទះដូចមិត្តភ័ក្តិដទៃដែរ ។ លុះចេញពីសាលាផុតបន្តិចមកក៏ប្រទះកញ្ញា**ណារី** ជាសិស្សរួមថ្នាក់ ត្រូវខូចកង់កណ្ដាលផ្លូវ។ ណារីជាក្មេងស្រីកំព្រាឪពុកម្ដាយរស់នៅជាមួយជីដូនជរា ក្នុងខ្ទមតូចមួយនៅភូមិជិតសេកដែរ ។ នាងមានកង់ចាស់មួយដែលជាយានជិះ ប៉ុន្តែទោចក្រយាននេះឧស្សាហ៍ខូចណាស់, ពេលនេះនាងដាក់ច្រវាក់ ហើយឡើងជិះបានបន្តិចក៏ធ្លាក់ទៀតជាញឹកញាប់ ។ ឃើញដូច្នេះទើបសេកចូលខ្លួនទៅជួយ:"ម៉េចណារី..កង់នាងខូចអីបានជាជិះឈប់ៗអញ្ចឹង?" ។

ណារីដែលកំពុងតែឈ្ងោកមើលកង់និងច្រវាក់, នាងងាកមកញញឹមស្ងួតប្រាប់ពីមូលហេតុ:

-មិនដឹងជាម៉េចវាទេ..បងសេកអើយ!ជិះៗធ្លាក់ច្រវាក់.!មើលពីសាលាដល់នេះធ្លាក់បួនប្រាំដងទៅហើយ!,

យុវជនសេកចូលទៅជិត រួចចាប់ច្រវាក់បង្វិលកង់ពិនិត្យមើលបន្តិចទើបពោល:

-ខ្ញុំសុំពិនិត្យមើលសិន.!ឱ.!មកពីច្រវាក់នេះវាធូរខ្លាំងពេកហើយ

បានជាអញ្ចឹង,

រួចសេកក៏ចាប់ទាញច្រវាក់មើលធ្វើមាត់ស្តែះ ណារីក៏សួរៈ

-ម៉េចទៅវាធូរពេកមែនទេ..បងសេក.? ,

គេទាញច្រវាក់មើលម្តងទៀតបង្ចើបកង់ហើយបង្វិល ទើបឆ្លើយៈ

-មែនហើយ..តែអាចកែកុនបាន!អញ្ចឹងអូសទៅតូបជួសជុលខាងមុខនោះទៅ! ,

ណារីនាងឈរកាន់ទប់កង់សម្លឹងមើលទៅតូបជួសជុលបន្តិច,ក៏គ្រវីក្បាលឆ្លើយៈ

-មិនបាច់ទេ..ព្រោះខ្ញុំអត់លុយជួសជុលផងហ្នឹង! ,

សេកញញឹមផ្តល់សេចក្តីសង្ឃឹមដល់នាងហើយនិយាយធានាៈ

-កុំព្រួយ..ខ្ញុំជាអ្នកធ្វើជូន!យើងគ្រាន់តែខ្ចីកូនសោឬម៉ាឡេតគាត់ទេតើ!,

នាងញញឹមយ៉ាងស្រស់សម្តែងការត្រេកអរចំពោះសេក,ដែលជួយខ្វល់ខ្វាយចំពោះរូបនាង ។

ណារីអូសកង់បណ្តើរនិយាយគ្នាបណ្តើរឆ្ពោះទៅតូបជាងជួសជុលកង់ ។

-បងសេក..សង្ឃឹមថាប្រឡងជាប់ដែរឆ្នាំនេះ?,ណារីផ្តើមសួរ ។





កម្លោះសេកលួចចោលកន្ទុយភ្នែកមើលនាង ហើយងាកមើលទៅមុខបន្តិច ទើបឆ្លើយដោយលាយភាពញញឹមតិចៗៈ

-សង្ឃឹមខ្លះៗដែរណារីឆ្នាំនេះ.. ប៉ុន្តែក្រសួងអប់រំបានកែច្បាប់ឱ្យរៀនដល់ថ្នាក់ទី៩ទើបប្រឡងឌីប្លូម.! ចុះណារីវិញ.? ,

-ខ្ញុំឆ្នាំនេះដូចជាពុំសូវសង្ឃឹមប៉ុន្មានទេ តែយើងមានឱកាសមួយឆ្នាំទៀតខំរៀន..ដើម្បីប្រឡងឌីប្លូមដែរ.! ។

លុះមកដល់រោងជាង,សេកបានសុំខ្ចីសោជួសជុល,គេបានមួលខ្មៅកង់ក្រោយបន្ធូររួចទាញបន្តឹងច្រវាក់ ហើយរឹតទៅវិញ។ គេឡើងជិះកង់ល្បងមើលបន្តិច ទើបប្រគល់ឱ្យណារីៈ

-ម្តងនេះល្អណាស់..ណារីមិនពិបាកទៀតទេ.!មើលទៅដូចជាប្រញាប់ផង..តើមានធុរៈអីឬ ?,

-ចាំស.! ប្រញាប់ទៅការិយាល័យ ICRC ស្រាវជ្រាវរកបងប្អូនដែលបែកបាក់គ្នាពីសង្គ្រាមណាំ.! ,ណារីឆ្លើយ ។

-អ្ហាក.! ណារីមានបងប្អូនបែកគ្នាពីសម័យមុននោះដែរ ?,

-ចាំសមាន! មានបងប្រុសម្នាក់នឹងប្អូនស្រីម្នាក់ឮថានៅកាណាដាឬអូស្ត្រាលីពុំប្រាកដ..អញ្ចឹងទើបប្រញាប់ទៅរកមើល.. ក្រែងគាត់ប្រកាសរក! ,

-ក៏ល្អដែរបើគាត់រកឃើង..ណារីកំពុងពិបាកពីរនាក់យាយផង.! ខ្ញុំក៏មានដែរបងស្រីម្នាក់ ឮថានៅអាមេរិកតែពុំដឹងរដ្ឋណាទេ.! .

-អញ្ចឹងខ្ញុំលាហើយណា៎.! ,ណារីឆ្លើយ ។

រួចនាងក៏ឡើងជិះកង់ទាំងក្តីរីករាយឆ្ពោះទៅការិយាល័យ ICRC នាក្រុងបាត់ដំបង ហើយយុវជនសេកក៏ដើរមកផ្ទះវិញដោយមានអារម្មណ៍រីករាយខុសប្លែកពីធម្មតាដែរ ។

* * *

## បងថ្លៃស្រវឹងស្រា

រសៀលនេះ សេកមកដល់ផ្ទះក៏ចាប់ផ្តើមលាងចានស្លាបព្រានឹងឆ្នាំងបបរទុកជាស្រេច ហើយទាញពូថៅមកពុះអុសបំបែក ដូចសព្វដងគេស្លៀកខោខ្លី ក្រមាក្រវាត់ចង្កេះ ប្រឹងពុះអុសបែកញើសគយៀរ ។

ខណៈនោះ ចិមជាបងថ្លៃបានដើរចូលមក ដោយអាការៈស្រវឹងស្រា,មានដំណើរទ្រេតទ្រោត ហើយក៏ដួលជ្រប់នៅមុខផ្ទះ សេកទំលាក់ពូថៅចុះស្ទុះរត់ទៅគ្រាហ៏:"បងយ៉ាងម៉េចហើយ.!នែ!ចន..អាចឹមអើយ..មកផ្ទះ! មកជួយរៀបកន្លែងឱ្យពុកឯងសម្រាកឮទេ!" ។





សេកគ្រាហ៏ផងស្រែកហៅក្មួយៗផង ក៏ត្រូវចិមជាបងថ្លៃងាកមកស្តីបន្ទោស:"នែ..!អញថ្លង់ណាស់អាសេកខំស្រែកចំទាលអី..ក្បែរត្រចៀកអញហ្នឹង ? តិចក្បាលនិងពូថៅចេញខួរឥឡូវហ្នឹងអ្ហែង!"។ ស្តីរួចក៏ឈរទប់ខ្លួនងាកមកទះកំផ្លៀងសេកមួយដៃ តែត្រូវសេកគេចផុត។ ភ្លាមនោះក្មួយទាំងពីរក៏មកដល់ ហើយចនបានជួយអន្តរាគមន៍។ ឯសេកលួងលោមបងថ្លៃ:"បង.!បងទៅសម្រាកសិនទៅ! ក្មួយចនទៅក្រាលកន្ទេលឯលើផ្ទះមុនទៅ..ឆាប់ឡើង!" ។

ចនក៏ស្ទុះឡើងទៅលើផ្ទះរៀបចំកន្លែងជូនឪពុកតាមបង្គាប់របស់ពូឯចិមបានងាកសម្លឹងមើលមុខសេក ហើយនិយាយហាក់មានកំហឹងកប់ទុកក្នុងចិត្តជាយូរមកហើយ:"ហ៊ឺស.!អាសំគិសឯងនេះល្មមដឹងខ្លួនហើយ ម៉្ងៗគិតតែពីស៊ីហើយដើរបាត់..អាងលេសរៀនសូត្រគ្មានជួយរកស៊ីអីសោះ!"។

សេកឮសំដីនេះគេនឹកសង្វេគខ្លួនជាខ្លាំង អារម្មណ៍បានគិតពិចារណាទៅសព្វគ្រប់ តែមិនបានចេញស្តីតបអ្វីទាំងអស់ ក្រៅពីលោមបងថ្លៃ: "បង.! បងទៅសម្រាកសិនទៅ!" ។

ចិមពុំបានស្តាប់ឬនៅស្ងៀមឡើយ គេនិយាយតាមតែនឹកឃើញជាភាសាអ្នកប្រមឹក:"ឯងនេះគ្មានចេះគិត...ពីភាពក្រីក្រក្នុងផ្ទះបន្តិចសោះឥឡូវបើមិនជួយធ្វើការរកស៊ីអីទេ ប្រញាប់ចុះចេញពីផ្ទះអញភ្លាមទៅឮទេ

អាសេក!" ។

សំដីពោលខ្លាំងៗបែបនេះ ធ្វើឱ្យសេកក្តុកក្តួលពេញឱរា ណានឹកខ្មាសអៀនអ្នកជិតខាងផង ណាអាណិតបងស្រីបង្កើត ម្ល៉ោះហើយក៏ខំខាំមាត់សង្កត់ចិត្តអង្វរលោមបងថ្លៃបន្តទៀតៈ"បង.! បងកុំមាត់ច្រើនអី..ឆាប់សម្រាកវិញ ព្រោះបងស្រវឹងខ្លាំងហើយណា!" ។

អ្នកចិមស្រវឹងមែនពិតតែនៅស្តាប់បានច្បាស់ទាំងអស់ សំដីសេកមួយមាត់នេះធ្វើឱ្យភ្លើងទោសៈបានផ្ទុះភ្លឺបមួយខណៈទៀត គេសម្លក់សេកថ្មៃ រួចទះកំផ្លៀងមួយដៃយ៉ាងខ្លាំងៈ"យើស.! ឯងហ៊ានប្រមាថថាអញស្រវឹងផងអ្ហែស..អាសេក! ផាង!" ។

សេកស្រែក"អូយ"នូវកណ្តាប់ដៃនេះ ហើយក្តោបមុខដើរចេញទុកអ្នកចិមឱ្យអង្គុយនិយាយម្នាក់ឯងក្បែរជណ្តើរ,ហើយក៏ទន់កល្ងៀកដេកផ្អែកលើកាំជណ្តើរនោះទៅ ។

មួយសន្ទុះក្រោយមក នាងសៀកបានត្រឡប់ពីផ្សារមកវិញឃើញចិមជាប្តីដេកនៅលើជណ្តើរ,ក៏ស្រែកសួរៈ"យីអើ.! ចុះអាមនុស្សធំៗទៅណាអស់ហើយ! អាចឹមម៉េចមិនជួយគ្រាហ៊ំពុកឯងទៅលើផ្ទះផង?" ។

ចឹមនៅក្បែរនោះបានដើរចូលមក,ព្រមទាំងនិយាយៈ"គ្រាហ៊ំអី ពូសេកគ្រាន់តែឃើញពុកអញ្ចឹង គេចបាត់មិនមកក្បែរផង! " ។





ចនជាបងរបស់ចឹមបានចុះពីលើផ្ទះមក គេមើលមុខចឹមជាប្អូនដោយហួសចិត្ត ទើបពោលបន្ទោសៈ"ម៉េចក៏ថាអញ្ចឹងអាចឹម..ពូខំគ្រាហ៊ំតែពុកជេរវាយគាត់ទេតើ! " ។

នាងសៀកជាម្តាយកាលបើកូនប្រកែកគ្នាបែបនេះ, ដៃម្ខាងកាន់កន្ត្រក ដៃម្ខាងលើកគ្រវាសឃាត់ចននឹងចឹមៈ"ណ្ហីយៗ.!ថ្លង់ណាស់ៗ.! ឈប់មាត់!ឥឡូវពូសេកឯងទៅណាហើយ..ហៅមកឱ្យជួយមួយភ្លែត!" ។

ពោលរួច នាងក៏យួរកន្ត្រកដើរចូលទៅទុកលើគ្រែខាងក្រោមផ្ទះ កូនទាំងពីររត់តាមម្តាយចូលឆែកកន្ត្រករកចំណី តែចនដើរចេញមកវិញនិយាយប្រាប់ម្តាយៈ"ពូសេកគ្រាហ៊ំដល់នេះ..ពុកវាយគាត់ ឥឡូវមិនដឹងជាទៅណាទេ! " ។

នាងសៀកឈរសញ្ជឹងគិតបន្តិច កាលបើឮកូនចនប្រាប់អំពើជាហេតុបែបនេះ រួចក៏នាំចននឹងចឹមចាប់គ្រាហ៊ំប្តីឡើងទៅលើផ្ទះ ។

# យល់សប្តិចម្លែក

រឿងរ៉ាវទាំងឡាយក្នុងផ្ទះនេះ បានចប់សព្វគ្រប់ទៅជាច្រើនថ្ងៃហើយ ឯសភាពអាប់អួបានក្លាយមកកាន់សភាពជាប្រក្រតីវិញ ប្រៀបបាននិងចានក្នុងរាវ ដែលតែងតែព្រួណ្តំគ្នាគ្រាមានចលនា ដែលគេលើកចុះឡើងដូច្នោះ ។

យប់នេះសេកបានអុជទៀនអានមេរៀននិងខំធ្វើលំហាត់ រហូតយប់ជ្រៅ ទើបក្រោកឡើងពត់ខ្លួនប្រាណ ទម្លាក់មុងពន្លត់ភ្លើងចូលដេក ហើយក៏លង់លក់ភ្លាមទៅ ។

ក្នុងរាត្រីនេះគេសុបិនយ៉ាងចម្លែក,វិញ្ញាណសេកបាត់រសាត់ទៅជួបកញ្ញាណារីនិងទីកន្លែងដ៏ចម្លែកមួយដែលស្ថិតនៅក្នុងវត្ត ។

ឯវិញ្ញាណណារីបានស្លៀកពាក់ស្អាតបាត កាន់ចានស្រាក់ចូលទៅថ្វាយបង្គំព្រះពុទ្ធបដិមាក្នុងព្រះវិហារនិងឈរពិនិត្យមើលផ្ទាំងគំនូរនៅតាមពិតាននឹងជញ្ជាំង រួចក៏ដើរចុះតាមទ្វារជណ្តើរទិសខាងត្បូង។ ពេលនោះសេកឃើញក៏ស្រែកហៅ: "អេ១ណារី.! ណារីមកទីនេះដែរ..តើមកជាមួយអ្នកណា?" ។





-ចាំស.! ខ្ញុំមកទីនេះដែរ..មកជាមួយយាយ.! .វិញ្ញាណណារីឆ្លើយដោយសម្លឹងពិនិត្យទៅសេក ឃើញស្លៀកពាក់ខោចាស់អាវយឺតដាចរយ៉ៃផង។

ឆ្លើយរួចនាងក៏ដើរក្បែរឃឿនព្រះវិហារ ឆ្ពោះទៅស្រះឈូកខាងកើត សេកក៏ដើរចូលទៅជិតធ្វើការស្និទ្ធស្នាល:

-ឥឡូវលោកយាយនៅឯណា.? ,

នាងក៏ឈរកាន់ចានស្រាក់សាសងគ្នាជាមួយកម្លោះសេក :

-ឱ.! គាត់នៅស្តាប់ធម៏ទេសនា..ឯខ្ញុំទៅផ្ទះមុន.! ,

សេកញញឹម ហើយប្រញាប់ពោល:

-ល្អហើយអញ្ចឹង..ខ្ញុំក៏ទៅផ្ទះដែរ.! ,

ទាំងពីរនាក់ដើរផងទស្សនានូវទិដ្ឋភាពសួនក្នុងទីអារាមផង, លុះមកដល់ទិសខាងកើតព្រះវិហារ នាំគ្នាឈរលើដីទួលខ្ពស់មួយកន្លែងមើលទៅឈើមួយដើមធំមានរូបសំណាកអ្នកតានៅក្នុងខ្ទមពីក្រោមផង។ សេកឈរពិនិត្យដោយពិចារណា,ឃើញដូច្នេះណារីក៏ស្រែកសួរ:

-បងសេកកំពុងឈរមើលអីហ្នឹង.? ,

សេកដែលឈរទ្រឹងពិនិត្យនោះក៏ភ្ញាក់អារម្មណ៍ងាកមកប្រាប់:

-មែនហើយនុះហ្ន៎.!ជាដើមធ្លកដែលត្រូវគេកាប់ចោលយូរហើយ

..ឥឡូវស្រាប់តែដុះឡើងវិញ! ណារីឃើញទេ.? .

គេចង្អុលទៅទីនោះបង្ហាញណារី ស្រាប់តែដើមធ្លកដ៏ធំក្លាយជាគល់ឈើមានត្រឹមតែគល់ ហើយពីគល់ដល់ប្រគាប មានប្រវែងប្រាំម៉ែត្រ តែពុំមានមែកធាងអ្វីទេ។ ណារីក៏ចម្លែកចិត្តដែរ នាងឆ្លើយជាបន្ទាន់:

-ចាស.!ឃើញៗ.! ហើយដូចជាមានរូបសំណាកថ្មនៅក្រោមនុំះទៀតផងហ្នុំ! .

សេកនាំណារីដើរវាងមកខាងមុខដើមឈើនោះ គេគិតថា:"ដើមធ្លកជាឈើកម្រប្រទះ មានសំបកក្រាស ផ្លែមានរសជាតិផ្អែមទៀត!"។

កំពុងតែពិចារណាពិនិត្យដើមធ្លក,លុះងាកមករកណារីវិញ ស្រាប់តែបាត់រូបនាងទៅ។ សេកបានរត់រកហើយស្រែកហៅនាង រហូតភ្ញាក់ដឹងខ្លួន ។

កាលបើភ្ញាក់ដឹងខ្លួនហើយ អារម្មណ៍គេនៅតែមានភាពរន្ធត់ដដែល គេពិចារណានូវសុបិននិម្មិតនេះបន្តិចក៏ឮសំឡេងចាបស្រុកស្រែកយំទ្រហឹងលើចុងស្វាយ ហើយហើរទំពីមែកមួយទៅមួយ ខ្លះមកទំលើសំយាបដំបូលផ្ទះ ទើបសេកភ្ញាក់ស្ទុះចុះរៀបចំបង្កាត់ភ្លើងដាំបបរ។ ភ្លាមនោះនាងសៀកក៏ស្រែកសួរ:"សេកអើយ!ម៉េចទៅបបរ..ឆ្អិនហើយឬ?"។

សំណួរនេះធ្វើឱ្យគេភ្ញាក់និងភិតភ័យជាខ្លាំង ព្រោះខ្លួនដេកជ្រុល





រហូតថ្ងៃរះខ្ពស់ទៅហើយ ។

បន្ទាប់ពីបង្កាត់ភ្លើងហើយ ស្ទុះទៅយកផ្តាំងមកលាងនិងច្រកអង្ករព្រមទាំងឆ្លើយផង:"ចែអើ្ហយខ្ញុំដេកជ្រុលទៅហើយ! ឥឡូវធ្វើម៉េចទៅបើថ្ងៃរះខ្ពស់ណាស់ហើយចែ?" ។

នាងសៀកដើរមកអង្គុយសំកុកនៅក្បាលជណ្តើរ ធ្វើមុខស្មៀកព្រោះខាតមុខរបរមួយថ្ងៃ តែនាងពុំទាន់ឆ្លើយជាបែបណាទេ ។

ឯអ្នកចិមជាប្តីបានស្លៀកខោ ហើយទាញអាវពាក់ដើរចុះមកព្រមទាំងស្តីបន្ទោសសេកផង:"អើវាសមហើយ.! ថ្ងៃនេះទើបចាប់ផ្តាំងបបរ..មនុស្សដែលគ្មានចិត្តគឺវាដេកគ្មានដឹងពេលវេលាអញ្ចឹង!"។ រួចក៏ចេញទៅបេនឡានបាត់ទៅ ។ នាងសៀកចុះពីជណ្តើរមកងើយមើលថ្ងៃ ឃើញរះផុតចុងឈើទៅហើយ ឯសេកកំពុងបង្កាត់ភ្លើងលាងផ្តាំង ទើបនាងឈរច្រត់ចង្កេះបញ្ចេញសម្លេង:"ម៉េច.!អា..បង្កាត់ភ្លើងបបរស្អីថ្នារហ្នឹង.?យកទៅលក់ពេលណា?ពន្លត់ភ្លើងហើយជះអង្ករចោលភ្លាម..មិនបាច់រកស៊ីអីទេឱ្យវាដេកងាប់ទៅ!" ។

សេកធ្វើមុខស្រពោន កាលបើត្រូវបងថ្លៃនិងបងស្រីស្តីបន្ទោសបែបនេះ គេចាប់នេះផុតចាប់នោះផុត ហើយនិយាយសូមទោស:"សូមទោសចែ..ខ្ញុំដេកជ្រុល ព្រោះមើលសៀវភៅយប់ពេក.!" ។

-អញ្ជើងថ្ងៃនេះស៊ីសៀវភៅទៅកុំស៊ីបាយ! ,នាងសៀកស្ដីបន្ថែម។

-អញ្ជើងគិតយ៉ាងម៉េចចែ? ខ្ញុំដាក់ទឹកដាំហើយណា៎! ,សេកសួរបញ្ជាក់បន្ថែមម្ដងទៀត ។

នាងសៀកក៏ផ្ទុះកំហឹងទៀតដែរ ខំបំប៉ោងសរសៃកស្រែកគំហកដាក់សេកជាប្អូន:"អញថាមិនបាច់ទេ.!ឯងថ្លង់ឬ.?នៅចចេសអីទៀត.!", នាងស្ទុះទៅលើកឆ្នាំងបបរពីចង្ក្រាន ហើយជះចោលនៅចំពោះមុខកម្លោះសេកប្រាវ ឆ្នាំងបបរខ្ទាតរមៀលឮឆុងឆាំងជាច្រើនត្រឡប់ទៅក្បែររបង។

សេកឃើញអាការៈបងស្រីបែបនេះ គេហាក់ស្រយុតស្លុតអស់ដួងចិត្ត ទង្វើបែបនេះក៏ពុំធ្លាប់មានតែម្ដងដែរ ទើបគេចចេញទៅក្បែររបងអង្គុយបណ្ដើរពិចារណាបណ្ដើរ:"ស្ដាយពុំគួរឱ្យធ្លោយការបែបនេះសោះ", មិនយូរប៉ុន្មានសេកក៏ស្ងប់អារម្មណ៍ទៅវិញ ព្រោះបងស្រីឈប់បន្តការស្ដីបន្ទោស ។

ប៉ុន្តែពេលនេះចឹមជាកូនទីពីររបស់សៀកបានចូលមកសួររកបបរ:

-ម៉ែទុកបបរឱ្យខ្ញុំមួយចានផង!,

នាងសៀកក៏ផ្ទុះអសុរសវាចាម្ដងទៀត:

--បបរអាប្រាសស្រុកអី.!បើអាកម្ទិលនោះវាដេកដល់ថ្ងៃចាំងក្បាលហើយហ្នឹង.! ,ព្រមទាំងលើកដៃរកខោកក្បាលកូនបញ្ឆោះឱ្យសេកផង។





តែកុមារចឹមពុំបានខ្លាចម្ដាយឡើយវាសួរទាររលុយទៀត:

-ខ្ញុំបានអីស៊ីព្រឹកនេះ.? អញ្ជើងឱ្យលុយខ្ញុំមក.! ,

នាងសៀកបើកភ្នែកធំៗសម្លក់ចឹមបន្តិច រួចក៏ដើរសំដៅពាងទឹករកលុបលាងមុខមាត់ ។ ចំណែកសេកឮក្មួយចឹមទាររលុយម្ដាយបែបនេះខ្លាចរំខានដល់ចិត្តបងស្រី និងអាចបណ្ដាលឱ្យមានការ ស្ដីបន្ទោសរាលដាលទៀត ទើបធានាឱ្យលុយ:"នែ.! ចឹមចាំពូឱ្យ!" ។

សេកដើរចូលមករកលុយទុកក្នុងសៀវភៅ,ឯចឹមរត់តាមយកលុយពីសេក។ ប៉ុន្តែសេករកលុយក្នុងសៀវភៅនោះមិនឃើញសោះ គេបើកផ្ទាត់ទំព័រមើលចុះឡើងយ៉ាងយូរ ធ្វើឱ្យចឹមរន្ថើនសួរទារ:"ឱ្យឆាប់ឡើងពូសេក!" ។

នាងសៀកបានត្រឡប់ពីពាងទឹកមក ឃើញសេកឈរបើកសៀវភៅក៏ស្រែកប្រាប់:"ម៉េចអាសេក.!ឯងមើលសៀវភៅមួយយប់ហើយ មិនទាន់អស់ចិត្តទេឬ.?នុះហ្ន៎.! ពាងរីងទឹកអស់ហើយ មិនគិតទៅអូសឬរែកមកប្រើទេអ្ហី?" ។

អ្នកកម្លោះកំពុងតែយកចិត្តក្មួយ,តែត្រូវរកមិនឃើញ ឥឡូវគេទុកសៀវភៅ ស្ទុះទៅរកអូសទឹកដាក់ពាងផ្គាប់ចិត្តបងស្រីសិន, ទើបងាកទៅអង្អែលក្មួយ: "មិនដឹងជាបាត់ទៅណាទេក្មួយចឹមអ្ហើយ.!ចាំពូមកពីអូសទឹក

វិញសិន!" ។

ចឹមពេលនេះ គេខឹងពូសេកជាខ្លាំង ហើយបែរទៅសុំលុយម្ដាយម្ដងទៀត :

-ឃើញទេពូឯងកុហក់មែន.! ម៉ែឱ្យលុយខ្ញុំមក.! .

នាងសៀកខាំមាត់ចង្កុលមុខចឹម,ហើយសម្លុតពេលសេកចេញផុត:

-នែ៎ៗអាចឹម.!ទៅបើកថ្ដាំងរកបាយខ្លះផងទៅ.!អញគ្មានលុយទេថ្ងៃនេះ! ហើយឯណាអាចនមិនប្រញាប់ទៅរៀនទេឬ..ថ្ងៃហើយណា៎?,

-ទៅម៉ែ.! តែចាំជួយដាក់ទឹកពូសេកសិន.! ,ចនឆ្លើយ ។

-មិនបាច់ទេ!ទៅរៀនឱ្យឆាប់ទៅក្រែងហួសពេល!,នាងដេញកូនឱ្យប្រញាប់ទៅសាលា,ហើយក៏ចាប់អំបោសជម្រះលំនៅឋានទាំងក្ដីមួហ្មង។

## អត់បាយធឺ

បន្ទាប់ពីអូសទឹកដាក់ពាង បានមួយធុងរួចមក សេកក៏ប្រញាប់ប្រញាល់ស្លៀកពាក់ចាប់សំពៀតស្ពាយ រត់ទៅកាន់សាលា ដើម្បីឱ្យទាន់ពេលវេលា ក្នុងចិត្តនឹកបារម្ភជានិច្ចថា: "ប្រហែលជាហួសពេលចូលរៀនហើយទេដឹងខ្ញុំ!"។





សេកខំស្ទុះរត់ផងដើរផងយ៉ាងញាប់ជើងទៅសាលារៀន, តែគេមានក្ដីមនោរម្យក្នុងចិត្តជានិច្ច ព្រោះបានឆ្លងកាត់ការស្ដីបន្ទោសផ្ទួនៗគ្នាក្នុងព្រឹកនេះ ។

ដើរមកដល់ផ្លូវជាតិ សេកក៏ប្រទះណារីកំពុងជិះកង់យ៉ាងលឿនហាក់ទើបនិងរួចកិច្ចការជាធុរៈនៅឯផ្ទះដូចខ្លួនគេដែរ ក៏ស្រែកហៅ :

-អ្ហែក! ណារី! ទើបតែមកដល់ទីនេះដែរឬ ? .

នាងងាកមកឃើញសេក កំពុងដើរយ៉ាងញាប់ជើង ទើបបង្អង់ល្បឿនកង់សួរទៅវិញ :

-ឱ! បងសេក ម៉េចក៏យឺតដែរថ្ងៃនេះ? .

-ណារីអើយ.!ខ្ញុំមានធុរៈខ្លះៗនៅឯផ្ទះ ទើបយឺតពេលយ៉ាងនេះ! ,សេកដើរផងឆ្លើយផង ។

ភ្លាមនោះ,ណារីបញ្ឈប់កង់ហើយចុះចេញអនុញ្ញាតឱ្យសេកឱបៈ

-អញ្ជើងជិះកង់ជាមួយខ្ញុំមក កុំឱ្យខកពេល! ,

អំពើល្អរបស់ណារីពេលនេះ ធ្វើឱ្យសេកមានអាការៈស្ទាក់ស្ទើរចិត្តបន្តិច ទើបពោលដណ្ដឹងចិត្តទៅវិញ:

-អ្ហេ!ដូចជាពុំសមទេដឹងណារី? . .

ណារីយល់ចិត្តសេក តែនាងបង្ខំដោយនិយាយថា:

-សមឬមិនសមកុំទាន់គិត ព្រោះថ្ងៃនេះយើងប្រឡងផងណា! ។

នេះជាលើកទីមួយហើយ ដែលសេកសម្រេចចិត្តជិះកង់ឌុបណារី ព្រមទាំងបង្ហាញភាពស្និទ្ធស្នាលគ្នា ដោយចៃដន្យ គេបានជិះឌុបនាងយ៉ាងលឿនឆ្ពោះទៅរហូតដល់សាលារៀន ។

លុះមកដល់ខ្លោងទ្វារសាលា,គេឃើញគ្រូបានប្រជុំជួរសិស្សគោរពទង់ជាតិទៅហើយ ទើបនាំគ្នាឈប់ឈរគោរពទង់ជាតិ ។ ហើយចូលទៅកាន់ថ្នាក់រៀនដោយពុំបានខកពេលប្រឡងឡើយ ។ ណារីងាកមកញញឹមហើយសួរដោយក្តីត្រេកអរ:

-បងសេក! ម៉េចទៅប្រឡងថ្ងៃនេះសង្ឃឹមដែរ.? .

សេកបានឆ្លើយដោយមានជំនឿក្នុងចិត្តយ៉ាងមុតមាំ:

-ប្រាកដជាសង្ឃឹមហើយ! ចុះណារីវិញយ៉ាងម៉េចដែរ.? ,

-ចំពោះខ្ញុំហាក់ពុំសូវសង្ឃឹមទេ ព្រោះរវល់ការងារផ្ទះពេក គ្មានពេលមើលសៀវភៅច្រើន.! .នាងឆ្លើយ ។

ការសន្ទនាត្រូវចប់ត្រឹមនេះ ព្រោះលោកគ្រូអញ្ជើញចូលដល់ហើយក៏ផ្តើមធ្វើការប្រឡងលើវិញ្ញាសាតាមកម្មវិធី ។ សេកគេខំប្រឹងធ្វើកិច្ចការនេះដោយយកចិត្តទុកដាក់បំផុតទាំងដោយមានក្តីសង្ឃឹមជានិច្ច ។

រយៈពេលមួយម៉ោងកន្លះកន្លងផុតទៅ គ្រូបានអនុញ្ញាតឱ្យអ្នក



លុយ សុខណ្ណា

ដែលធ្វើកិច្ចការរួចចេញសម្រាកខាងក្រៅមុន ។ សេកចេញមកអង្គុយលើបង់ថ្មមួយក្រោមដើមឈើមើលសៀវភៅ ឯសិស្សភាគច្រើននៅក្នុងបន្ទប់ប្រឡងនៅឡើយ ។

គេអង្គុយបើកសៀវភៅពិនិត្យនូវប្រធានបទប្រឡង ដែលទើបធ្វើរួច ឃើញថាខ្លួនគេធ្វើត្រូវបានច្រើន ។ យូរបន្តិចមកការបន្លឺសំឡេងជួងបានរោទិ៍ឡើង"ម៉ុងៗម៉ុងៗ!"នេះជាសំឡេងជួងប្រាប់ថា ដល់ម៉ោងសម្រាកបំបែកគ្នាទៅផ្ទះរកអាហារថ្ងៃត្រង់រៀងៗខ្លួន ។

ការប្រឡងព្រឹកនេះធ្វើឱ្យសេក ភ្លេចអស់ភាពសៅហ្មងដែលកន្លងផុតទៅ ប៉ុន្តែពេលឈានជើងចូលដល់មុខផ្ទះ សភាពដែលគួរឱ្យសោកសៅនោះបានផុះឡើងវិញ ។

សេកដើរចូលទៅក្រោមផ្ទះហើយផ្លាស់សម្លៀកបំពាក់ ទើបចូលទៅបើកឆ្នាំងរកបាយបរិភោគ តែឆ្នាំងទទេគ្មានបាយមួយគ្រាប់សោះ។ក្នុងចិត្តសេកក្តុកក្តួលរំជួលជាខ្លាំង ទឹកភ្នែករលីងរលោង គេខំទប់ចិត្តសង្វេគលួចជូតទឹកភ្នែកដៃម្ខាង ដៃម្ខាងកាន់ចានស្លាបព្រា ងាកទៅសួរក្មួយចនដែលដេកលើអង្រឹងក្បែរផ្ទះបាយ:

-ក្មួយចន!ឯងមិនទាន់ញាំបាយទេឬ?.

ចនឆ្លើយទាំងពុំដឹងរឿងថា:

-ខ្ញុំញាំរួចហើយពូ! ហើយម៉េចក៏នៅយូរម្ល៉េះព្រឹកនេះ?.

-អើ! ព្រោះជាប់ប្រឡងឡើងថ្នាក់ អញ្ចឹងទាំងអស់គ្នាបាយរួចហើយឬ ?.

-បាទរួចគ្រប់គ្នាហើយ...នៅសល់ប៉ុន្មានគឺពូហើយ! ,ចនតប ។

សេកធ្លាក់ទឹកមុខជ្រប់កាលបើឮពាក្យក្មួយប្រាប់បែបនេះ គេបានដឹងដល់មូលហេតុ ទើបសុំឱ្យចនជួយបង្កាត់ភ្លើងដាំបាយ:"ចន! ក្មួយជួយបង្កាត់ភ្លើងឱ្យពូបន្តិច ពូលាងឆ្នាំងច្រកអង្ករ" ។ ចនបានចុះពីអង្រឹងទៅបើកឆ្នាំងផ្សេងៗទៀត ឃើញថាគ្មានបាយ ទើបច្រៀកចម្រៀកអុសជួយបង្កាត់ភ្លើងដោយចិត្តងឿងឆ្ងល់ ។

កាលបើភ្លើងឆេះ ឯសេកកំពុងតែលាងឆ្នាំងនោះ នាងសៀកបានស្ទុះចុះពីលើផ្ទះមកស្រែកឃាត់:"មិនបាច់បង្កាត់ទេអាចន!បាយថ្ងៃនេះអញដាំសម្រាប់តែគ្នាប៉ុន្មាននាក់ក្នុងផ្ទះនេះទេ ឯអាអ្នកខ្ជិល គ្មានអង្ករគ្មានបាយទេ!" ។

ហើយក៏ងាកទៅយកទឹកមកជះពន្លត់ភ្លើងក្នុងចង្ក្រាន:"ឈប់!ឈប់ភ្លាមអាចន..ពន្លត់ភ្លើងវិញភ្លាម.!" ។ នាងបានជះទឹកពន្លត់ ហើយក៏ទៅទាញកន្ត្រាក់ឆ្នាំងពីដៃសេកមកព្យួរទុកវិញ ។ សេកឃើញសកម្មភាពនេះក៏ឈរធ្មឹងដូចរូបចម្លាក់គ្មានវិញ្ញាណត្រចៀកគេហាក់គ្មានឮសំឡេងអ្វីដែល





នៅជុំវិញខ្លួនទាំងអស់ ។ មួយសន្ទុះក៏មានចលនាដើរតិចៗទៅអង្គុយលើអង្រឹង បណ្ដែតមនោគតិទៅកាន់ទីដ៏សែនឆ្ងាយ ដោយពុំចាប់អារម្មណ៍មើលនាងសៀកកំពុងសម្លក់សម្លឹងស្ទើរតែចង់ស៊ីសាច់គេនោះឡើយ ។

បន្ទាប់ពីបន្ទោបង់ភាពសៅហ្មងក្នុងដួងចិត្តបន្តិចមក គេស្វាងអារម្មណ៍មកវិញនៅពេលឮចនសួរម្ដាយ: " តើពូគាត់បានអីពិសា បើម៉ែមិនឱ្យគាត់ដាំបាយអញ្ចឹង?" ។

នាងសៀកជាម្ដាយបានខ្នាក់កំហឹងដាក់ចនជាកូនទៀត:"ឯងកុំចេះដឹងពេកអាចន តិចអត់ទាំងម្ហូងទៀតឥឡូវហ្នឹង!" ។ គ្រានោះសេកក្រោកពីអង្រឹងទៅទាញអាវនិងសំពៀតសៀវភៅ ស្ពាយដើរចេញទៅសាលារៀនវិញ ។

គេមានសភាពរសេះរសោះហត់ហេវជាខ្លាំង ព្រោះគ្មានបាយឆ្អិនិងគ្មានកម្លាំងចិត្តបន្តិចសោះ.គេគិតថា"បើសិនជាចែសៀកមិនឱ្យបាយស៊ីមិនឱ្យផ្ទះជ្រក តើនិងទៅទីពឹងអ្នកណា ព្រោះនេះជាតម្រុយនៃការផ្ដាច់មនោសញ្ចេតនាជាបងប្អូនក្នុងគ្រួសារមកលើរូបខ្ញុំហើយ មិនយូរមិនឆាប់គង់នឹងកើតឡើងនូវរឿងនេះ តាមមើលទៅសព្វថ្ងៃនេះ ខ្ញុំជាឆ្អឹងជាប់នៅបំពង់កបងថ្លៃនិងបងស្រីជាប្រាកដ" ។ គេដកដង្ហើមធំបន្ទោបង់ភាពក្ដុកក្ដួលនេះចេញពីទ្រូងបន្តិច ទើបទៅអង្គុយលើបង់មួយមុខសាលា បើក

មើលសៀវភៅពិនិត្យមេរៀន ។ ស្រាប់តែឃើញលុយប៉ុន្មានរៀននៅក្រប សន្លឹកទំព័រ:"អ្ហាក! លុយ៥០០រៀលនៅក្នុងសៀវភៅនេះទេតើ! គិតទិញ អីផីអញ្ចេះខ្ញុំ!" ។

គេត្រេកអរព្រួច ព្រោះក្រពះកំពុងទាមទារអាហារជាខ្លាំង។ នៅក្បែរនោះមានរានលក់ចំណីពីរបីកន្លែង។ សេកគិតថា:"គួរទិញចេកទុំវិញ ព្រោះនិងសំចៃទុកសម្រាប់ពេលល្ងាចបានខ្លះទៀត!" ។

សេកទិញចេកមកឆីយ៉ាងឆ្ងាញ់ អស់មួយថែមមួយ រហូតអស់ ដោយភ្លេចសំចៃទុក ដូចដែលបានគិត ហើយពិចារណាថា:"លុយនេះ ហើយដែលខ្ញុំគិតឱ្យក្មួយចីមកាលពីព្រឹកមិញ តែរកមិនឃើញ! ម៉េចក៏មកនៅក្នុងសៀវភៅនេះទៅវិញហ្ន៎?" ។

នៅបរិវេណសាលានេះ យើងឃើញមានសិស្សសាលាមួយចំនួន ដែលខ្ចប់បាយមកបរិភោគ ដោយហេតុតែផ្ទះពួកគេនៅឆ្ងាយៗពីសាលារៀន ។ ទិដ្ឋភាពសិស្សទាំងនោះបានជួយលុបបំបាត់ក្តីក្រៀមក្រំ ដែលកំពុងកើតមានក្នុងចិត្តសេកបានមួយខណ:ខ្លះៗដែរ ។ គេមានទឹកមុខស្ទើបែបស្រស់បស់បន្តិចចាប់សៀវភៅមកអានបន្តទៀត.ស្រាប់តែ"បងសេក!" កញ្ញាណារីបានដើរលបៗមកពីក្រោយសេក ហើយពញ្ញាក់ធ្វើឱ្យសេកភ្ញាក់ ទើបសួរ:"យី!មកសម្ងំរៀនពីពេលណាមកហ្នឹង ហើយម៉េចក៏មានមុខស្ទើ





ស្លេីកៗអញ្ចឹង?" ។

ពេលនេះសេកបានអញ្ជើញណារីឱ្យអង្គុយលេងជាមួយ ព្រមទាំងងាកខ្លួនទុកកន្លែងជូននាង:"អើ.!មកអង្គុយលេងណារី.! ខ្ញុំមកយូរហើយ ម្យ៉ាងខ្លាចតែប្រឡងធ្លាក់ ទើបមុខខ្ញុំបែបនេះណា៎!" ។

-ណ្ហើយ..បងសេកអ្ហើយ.!យើងខំរៀនដែរបើសិនជាធ្លាក់ទៀតនោះ មិនគួរខ្មាសគេទេ!ខ្ញុំឃើញអ្នកខ្លះមិនដែលកាន់សៀវភៅអានផងគេ ហាក់គ្មានខ្វល់អីសោះ! ,នាងពោលផងបោសធូលីកន្លែងអង្គុយផង ។

សេកគេយល់ស្រប.ទើបបង្វែរសំណួរ:

-អើ! ណារីម៉េចទៅ.! ថ្ងៃមុនទៅ I C R Cរកបងប្អូនឃើញ ដែរ?,

នាងត្រេកអរជាខ្លាំង ហើយទះដៃឡើងនិយាយប្រាប់សេក: "ឱ! ឃើញហើយៗ បងប្អូនខ្ញុំទាំងពីរអ្នកហ្នឹងនៅអូស្ត្រាលី.! អ៊ូ.! ខ្ញុំដូចជាបានឃើញឈ្មោះបងស្រីម្នាក់ប្រកាសរកបងប្អូន ដែលរស់នៅភូមិបេងឃុំអន្លង់វិលនេះដែរណា៎ !" ។

សេកបើកភ្នែកចាប់អារម្មណ៍ដោយក្តីរំភើប ហើយសួរបញ្ជាក់ :

-បងស្រីនោះឈ្មោះអី.! រូបរាងក្នុងរូបថតយ៉ាងម៉េចដែរ ? .

ណារីសញ្ជឹងគិតរកនឹកបន្តិចទើបប្រាប់:

-ឱ.!ចាំមិនបានទេបងសេក ព្រោះរវល់តែអរនិងការរកឃើញបងប្អូន..មែនហើយបងគួរតែទៅមើលមួយភ្លេតទៅ !.

-អរគុណណាស់ហើយ!ចាំពេលរសៀលខ្ញុំនឹងទៅមួយភ្លេត!.សេកពោល ។

ការប្រឡងនៅពេលរសៀលនេះ បានប្រព្រឹត្តទៅរយៈពេលមួយម៉ោងកន្លះ សេកបានបញ្ចប់កិច្ចការសាលា ហើយបានពឹងមិត្តម្នាក់ឱ្យជូនទៅការិយាល័យ I C R C ក្រុងបាត់ដំបង ដើម្បីពិនិត្យមើលសេចក្ដីប្រកាសនោះ ។

សេកពុំបានគិតពិនិត្យមើលរូបថត ដែលគេតាំងនៅលើក្ដារខៀនមុខការិយាល័យនោះទេ គេមើលតែអាស័យដ្ឋានប៉ុណ្ណោះ ។ ស្រាប់តែប្រទះលិខិតប្រកាសមួយសន្លឹក ដែលនិយាយឈ្មោះសេកនិងនាងសៀកជាបងស្រី សេកញ័រដៃជើងអានភ្លាម :

<u>**ដំណឹងប្រកាសរកគ្រួសារ**</u>

នាងខ្ញុំឈ្មោះ សុខ សោម អាយុ៣៥ឆ្នាំសព្វថ្ងៃរស់នៅសហរដ្ឋអាមេរិកក្នុងរដ្ឋម៉ាសាជូសិត ។

សូមប្រកាសរកប្អូនទីបីឈ្មោះ សុខ សៀកភេទស្រីអាយុ៣០ឆ្នាំ និងប្អូនទីប្រាំឈ្មោះ សុខ សេក ភេទប្រុស អាយុ២៣ឆ្នាំ





សព្វថ្ងៃរួចថារស់នៅភូមិបេងស្រុកសង្កែ ខេត្តបាត់ដំបង តែពុំដឹងឃុំ ។

ហេតុនេះ បើប្អូនទាំងពីរឬបងប្អូនណាបានស្គាល់ សូមមេត្តាជួយផ្ដល់ដំណឹងនិងទាក់ទងតាមអាស័យដ្ឋានដូចខាងក្រោម :

M.RS.Soum Sok,M.A.TO.12 U.S.A

TEL : 012 695 245 ។

សូមអរគុណ

ឆាន់ជាមិត្តភ័ក្ដិដែលជូនដំណើរសេកទៅនោះ,ឃើញសេកពិនិត្យអានសេចក្ដីប្រកាសនោះ គេឆ្ងល់ជាខ្លាំងថា : "ហេតុម៉េចបានជាចាប់អារម្មណ៍និងលិខិតប្រកាសមួយសន្លឹកនេះជាងគេម្ល៉េះ?" ។

សេកបានពន្យល់ប្រាប់ឆាន់នូវសេចក្ដីនេះសព្វគ្រប់ មានបង្ហាញនូវអាស័យដ្ឋានឯសហរដ្ឋអាមេរិកនិងឈ្មោះភូមិស្រុកខេត្តច្បាស់លាស់ផងលើកលែងតែឃុំប៉ុណ្ណោះ ។ ហើយសេកក៏បានចង្អុលបង្ហាញប្រាប់ឆាន់នូវអាស័យដ្ឋាននៅលើក្រដាសនោះឱ្យគេជួយពិនិត្យទៀតផង ។ ឆាន់ពិនិត្យហើយជួយត្រេកអរជាខ្លាំង,គេសួរ: "ឯងចាំណាំរូបគាត់បានដែរឬសេក?", សេកសញ្ជឹងគិតបន្តិច,គេគ្រវីក្បាល : "ចាំណាំពុំបានទេព្រោះនៅតូចពេកកាលដែលបែកគ្នានោះ ប៉ុន្តែចែសៀកទើបគាត់ច្បាស់ !" ។

ភម្លោះឆាន់បានប្រាប់ឱ្យសេកសរសេរសំបុត្រ ផ្ញើទៅសួរសុខទុក្ខគាត់ ។ សេកងក់ក្បាល ហើយទាញក្រដាសនិងប៊ិចមកកត់ចម្លងសេចក្ដីប្រកាសនិងអាស័យដ្ឋាននេះដោយផ្ទៀងផ្ទាត់ ហើយឆាន់ក៏នាំសេកមកផ្ទះវិញ ។

ពេលមកដល់មុខផ្ទះ,សេកហាក់ញញើតនិងការបង្ហាញខ្លួនចំពោះមុខបងជាខ្លាំង ព្រោះនឹកឃើញដល់ការស្ដីបន្ទោសនិងការស្អប់ខ្ពើមរហូតដល់បង្អត់បាយកាលពីថ្ងៃកន្លងមកនេះ ។ លុះនឹកដល់ការរកឃើញបងស្រីនៅសហរដ្ឋនោះ ទើបគេខំសម្រួលអារម្មណ៍ឡើងវិញ ហើយដើរចូលទៅជួប ដោយធ្វើអាការៈញញឹមអិមអៀមដាក់បងស្រី ។

នាងសៀកឃើញសេកដើរចូលមក នាងមានចិត្តក្ដៅឆួលឡើងភ្លាមធ្វើមុខក្រញ៉ូវងាកចេញមិនស្ដី ហើយត្រៀមក្របួចមាត់និងស្ដីជេរសេកឱ្យចាស់ដៃថែមទៀតផង ។ សេកដឹងចិត្តក៏តាំងស្មារតីក្លាហាននិយាយៈ "ចែអ្នា.!ចែ.! ខ្ញុំមានដំណឹងមួយ.!",នាងសៀកមិនចេញស្ដីរក តែដៀងភ្នែកសម្លក់តបដោយមិនមើលមុខ ។ សេកយល់ថាជាការពុំគួរបង្អង់យូរទើបរៀបរាប់ពីមូលហេតុប្រាប់ភ្លាម : "ខ្ញុំរកឃើញអាស័យដ្ឋានចែសោមហើយ សព្វថ្ងៃគាត់រស់នៅអាមេរិក!" ។ ឮដំណឹងនេះនាងសៀកហាក់របូតកំហឹងពីទ្រូងភ្លាម ទឹកមុខកំណាចក្លាយជាស្រស់ថ្លា ញញឹមមើលមុខ





ប្អូនហើយសួរបញ្ជាក់ :

-ឯងបានដំណឹងនេះពីណា ? នរណាប្រាប់ទើបដឹង ?.

-នេះអាស័យដ្ឋានគាត់ ខ្ញុំទៅឯការិយាល័យ I C R Cពិនិត្យមើលប្រកាស..ស្រាប់តែឃើញ.! ,សេកហូតក្រដាសកត់អាស័យដ្ឋានមកបង្ហាញ ។

កម្លោះសេកត្រេកអរណាស់ បានបងស្រីមិនស្ដីបន្ទោស ឯនាងសៀកពេលនេះក៏រំសាយគំនុំនឹងប្អូន និយាយរួសរាយរាក់ទាក់ដូចដើម : "អើ ! អាស័យដ្ឋាននេះប្រាកដជាចែសោមមែនហើយ ",នាងស្ទុះមកទះស្មាសេកពោលសរសើរៈ"យី.! អានេះឆ្លាតណាស់តើ.! ចេះរកចែសោមឃើញ.! អើ.! ឥឡូវជិតយប់ហើយ ចាំស្អែកនឹងទៅទូរស័ព្ទជួបគាត់.! ឯងជួយពុះអុសដាំបាយផង..អញទៅផ្សារមួយភ្លែត !".

សេកសប្បាយចិត្តលើសពេលណាៗទាំងអស់ ប្រៀបអ្នកជម្ងឺក្ដៅសន្ធំហើយត្រូវថ្នាំត្រជាក់ដូច្នោះ គេប្រញាប់ស្ទុះទៅចាប់ពូថៅ មកពុះអុសបំបែកភ្លាម ។

គេប្រមូលអុសចូលទៅបង្កាត់ភ្លើងចាប់ផ្ដាំងបាយលាង ហើយច្រកអង្ករដណ្ដាំស្លដោយរីករាយ ។ យុវជនសេកខំធ្វើអាហារល្វាចយ៉ាងញាប់ដៃជើង ម្យ៉ាងដោយក្ដីឃ្លានពេញមួយថ្ងៃមកហើយផង ។ គេដួសបាយ

មកភ្លក្សនឹងដុំអំបិលយ៉ាងឆ្ងាញ់ផ្អែមមាត់ ។ គំនិតគេពេលនេះគ្មានគិតអ្វីក្រៅពីកុំឱ្យអ្នកផ្ទះទាំងអស់ខឹងស្អប់ឡើយ ។

## អាឡូអូន! អាឡូបង!

ព្រឹកនេះបន្ទាប់ពីធ្វើបបរួចរាល់ហើយនាងសៀកបង្គាប់ឱ្យសេករៀបចំនិងរែកទៅលក់ឯរានផ្សារ។ សេកបានរែកជញ្ជូនឆ្នាំងបបរទៅរៀបចំជូនបងស្រីដូចសព្វដង ប៉ុន្តែពេលនេះយុវជនយើងត្រូវមកអង្គុយលក់ម្តងវិញ។ ចំណែកនាងសៀក បានស្លៀកពាក់ស្អាតសមរម្យជាមួយនឹងចិមជាប្តី.បណ្តើរគ្នាទៅកាន់ក្រុមហ៊ុនទូរស័ព្ទក្រៅប្រទេសនៅឯទីក្រុងបាត់ដំបង។

ភ្នាក់ងារទូរស័ព្ទនាំសៀកចូលបន្ទប់កញ្ចក់តូចមួយ ហើយក៏ហុចទូរស័ព្ទឱ្យនាងនិយាយទាក់ទង :

-អាឡូ.!អាឡូ.! អ្នកណាហ្នឹង.? ,អ្នកសោមជាបងនៅឯសហរដ្ឋអាមេរិកទទួលហើយសួរ ។

-អាឡូ.!អាឡូ.! ចាស.!ខ្ញុំឈ្មោះសុខ សៀកចាស! ,នាងសៀកឆ្លើយ ។

-អ្ហាក.!អូនសៀកឬ? អើ.! សព្វថ្ងៃនៅខេត្តណា.?ហើយអាអូនសេកយ៉ាងម៉េចដែរ ?,





-ចាសចៃ.!ខ្ញុំនៅឃុំអន្លង់វិលស្រុកសង្កែខេត្តបាត់ដំបង.!អាសេកនៅជាមួយខ្ញុំចៃ! ហើយចៃនឹងបងប្រុសអីសុខសប្បាយជាទេឬ ?,

-អើ.! បងនឹងក្រុមគ្រួសារសុខសប្បាយទាំងអស់គ្នា.! ឯអូនវិញមានកូនប៉ុន្មាននាក់ ? ហើយធ្វើការងារអីសព្វថ្ងៃ ?,

ពេលនេះ នាងសៀកបានរៀបរាប់ទាំងរអាក់រអួលដើមកប្រាប់បងស្រីនូវភាពវេទនា និងក្តីនឹករឭកប្រាប់ទៅនាងសោមជាបងស្រី :

-ចៃអើ្អយ.!កូនពីរបីនាក់.! តែប្អូនគ្មានស្រែចម្ការអីទេ..សព្វថ្ងៃលក់បបរនៅផ្សារស្រុកសង្កែណាចៃ.!,

នាងសោមឮសំដីប្អូនស្រីរអាក់រអួលបង្ហាញនូវទុក្ខវេទនា ក៏លួងលោមឱ្យមានក្តីសង្ឃឹម ដោយសន្យានិងជួយគ្រប់យ៉ាង ពិសេសគឺសេកជាប្អូនពៅដែលនៅជាមួយ ហើយកំពុងតែសិក្សា :

-អើ.!អូនអ្ហើយកុំបារម្ភអី..បងនិងជួយណា៎.!ឥឡូវអាអូនសេកវារៀនដល់ថ្នាក់ណាហើយ ?,

នាងសៀកទាញក្រមាញើសសំបោរបន្តិច ទើបឆ្លើយៈ"ចាស.!វារៀនប្រឡងឌីប្លូមឆ្នាំក្រោយ..ប៉ុន្តែខ្ញុំខ្វះមុខខ្វះក្រោយពុំដឹងជាយ៉ាងណាទេចៃ.! ,

-តែពេលនេះប្អូនត្រូវជម្រុញឱ្យវាខំរៀនបានខ្ពង់ខ្ពស់ឡើង បងធា

នាជួយវាទាំងអស់ឮទេ?ឥឡូវវាមកជាមួយដែរទេ?ឱ្យជួបបងបន្តិចមើល!,

នាងសៀកឮថាជួយសព្វបែបយ៉ាងដូច្នេះ រំភើបចិត្តខ្លាំងណាស់ ទើបរៀបរាប់រឿងសេក :

-វាមិនបានមកទេ..ចែអើយ.! អូនសេករៀននេះ..ខ្ញុំខំលក់បបរ ទិញខោអាវប្រដាប់ប្រដា..និងបង់ថ្លៃសាលាគ្រប់សព្វ.! ណាកូនរៀនទាំងអស់ទៀត ខ្ញុំគិតថាឱ្យវាឈប់ហើយជួយរកស៊ីវិញឥឡូវបានចែជួយឧបត្ថម្ភអញ្ចឹងជាការល្អណាស់...យើងនិងបណ្ដុះវាឱ្យអស់ពីសមត្ថភាពណាចែ.!,

-អើឱ្យវាខំរៀនចុះ.!ហើយប្ដីប្អូនរកស៊ីអីដែរ.?ឯក្មួយៗរៀនថ្នាក់ទីប៉ុន្មានខ្លះ ?

-ចាំស.! ប្ដីខ្ញុំធ្វើកម្មករគាក់ស៊ី..ឯកូនខ្ញុំអាទីមួយរៀនថ្នាក់ទី៥.! ទីពីរថ្នាក់ទី៤ ណាចែ !,

-ឱ.!ប្ដីអូនឯងចេះបើករថយន្តដែរមែនទេ? ,សោមបញ្ជាក់ហាក់មានគម្រោងនិងជួយ ។

-ចាំស..!គាត់ចេះណាចែ.! ,សៀកឆ្លើយដោយបង្កប់ក្ដីសង្ឃឹមបញ្ជាក់ប្រាប់បងស្រី ។

-បើចេះ..ចាំបងគិតគូរមើល.!ឥឡូវបងផ្ញើឱ្យអូនប្រាំបីរយដុល្លារ ឱ្យអាអូនសេកប្រាំរយដុល្លារ តើផ្ញើតាមណាទើបដល់ប្អូន ?,



ឈុយ សុខណ្ណា 

-ឱ.!សាធុ..សាធុ.! ខ្ញុំអរគុណខ្លាំងណាស់ចែ.! ចែអ្នា.!ផ្ញើតាមក្រុមហ៊ុននេះមកដល់ខ្ញុំហើយ.!សូមចែនិងគ្រួសារជួបតែក្ដីសុខគ្រប់ប្រការ!,

-សាធុ..សាធុ.! អើប្អូនក៏សុខសប្បាយទាំងអស់គ្នាដែរ.!ហើយកុំភ្លេចឱ្យអាអូនសេកមកជួបបងកុំខានណាំ.!លាហើយចាំទូលលុយចុះ បីថ្ងៃទៀតដល់ហើយ.! ,

នាងសៀកពេលនេះហាក់មានស្លាបហោះដូចជាបក្សា,គេសប្បាយរកអ្វីប្រៀបគ្មានព្រោះជួបបងស្រីចិត្តធម៌។ នាងបានធ្វើទំនាក់ទំនងជាមួយក្រុមហ៊ុនទូរស័ព្ទ ដើម្បីចាំទទួលលុយជាស្រេច ទើបប្រញាប់ប្រញាល់មកផ្ទះវិញ។

***

## លក់បបរមិនអស់

ពីព្រលឹមរហូតថ្ងៃជិតត្រង់ទៅហើយ សេកថ្មីត្បិតតែគេធ្លាប់កាន់កន្ត្រកឡើងផ្សារ,ធើបដាំបបរនិងរែកបបរមកដាក់រានរៀបចំឱ្យបងស្រីលក់ដូរ ប៉ុន្តែលុះមកអង្គុយលក់ដូចថ្ងៃនេះគឺគេពុំធ្លាប់ឡើយ ។ ដូច្នេះក្នុងចិត្ត

គេមានក្ដីខ្មាសអៀនមហាជនជាខ្លាំង ទឹកមុខមិនស្រស់ថ្លា អង្គុយឧស្សាហ៍ពត់ខ្លួន ព្រោះដងខ្លួនគេហាក់ដូចជារឹងឆ្អឹង មិនសូវហ៊ានងាកមើលគេឯងឡើយ ។ បបរក៏លក់មិនអស់ ពុំដឹងជាអតិថិជនខ្មាសអ្នកលក់ឬអ្នកលក់ថ្មីមិនចេះរួសរាយហៅភ្ញៀវ ទើបត្រូវនៅសល់ច្រើនបែបនេះ ។

សេកនឹកខ្វល់ណាស់ ណាខ្លាចបងស្រីស្ដីបន្ទោសផង ណាខ្មាសខ្លាចអ្នករៀនដូចគ្នាឃើញផង។ នេះជាទម្លាប់កម្លោះខ្មែរមួយចំនួន ដែលតែងតែមានការអៀនខ្មាស់ ក្នុងកិច្ចរកស៊ីដូចជាស្ត្រីបែបនេះ ។

គេងាកមើលថ្ងៃដែលកំពុងរះខ្ពស់លើវេហាស៍ ហើយចាប់វែកកូរមើលបបរក្នុងឆ្នាំង ទើបងាកមករាប់លុយដែលលក់បាន ។ ក្នុងចិត្តពិចារណា:"បើលក់បានរួចដើមនោះមិនសូវជាអីទេ តែបើខាតវិញច្បាស់ជាត្រូវថៃស្ដីបន្ទោសទៀតហើយ".គេដកដង្ហើមធំ"យូរ". លុះរាប់លុយរួច យើងសង្កេតឃើញមានស្នាមញញឹមតិច១ បញ្ជាក់ថាសេកគេលក់បានរួចដើមឬក៏ចំណេញខ្លះមិនខាន។ សេកគិតថា:"គួរចែកអ្នកជិតខាងឱ្យអស់ ដើម្បីកុំឱ្យថៃសៀកឃើញថា នៅសល់ច្រើន ប៉ុន្តែមិនអាចធ្វើទៅបានឡើយ ប្រាក់ចំណូលប៉ុណ្ណឹងមិនសមនិងបបរមួយឆ្នាំងនេះទេ". កំពុងតែគិតស្រាប់តែណារីចេញពីផ្សារដើរតម្រង់មក ព្រមទាំងសួរ :

-យី..បងសេក.! លក់បបរដាច់ដែរថ្ងៃនេះ?.នាងនិយាយ ព្រម





ទាំងញញឹមរួសរាយ ។

សេកកំពុងតែខ្មាសអៀន.ងាកមកឃើញណារីនៅជិតបង្កើយក៏ផ្ទុះឧទាន :

-អ្ហាកណារី.! ទិញអីខ្លះថ្ងៃនេះ ?.គេសួរដោយអាការ:អឹមអៀមព្រោះខ្មាស់នាង ។

នាងញញឹមឆ្លើយ:

-ចាស.!ទិញគ្រឿងកកូរ.! អេ.!មកលក់រាល់ថ្ងៃឬ..បងសេក?.

កម្លោះសេកសើចញញឹម១ឆ្លើយ:

-ទេ..ណារីអើយ.!ទើបតែថ្ងៃនេះទេ ហើយលក់មិនដាច់ទៀតមកពិសាមួយចានមើលណារី.!.

-ទេ..ទេ.!ដូចជាអត់ឃ្លានផង.! .ណារីប្រកែក ព្រោះនាងគ្មានលុយសល់ ។

មិនបង្អង់យូរសេកអញ្ជើញនាងឱ្យអង្គុយចុះ ហើយចាប់ចានដួលបបរដាក់ពេញហុចជូនភ្លាម ព្រមទាំងពោល:

-នេះនែ.!ពិសាសាកមើលណារី..ឆ្ងាញ់ណាស់ណា! .

ឃើញដូច្នោះ នាងលូកដៃទទួល ព្រមទាំងពោល ដោយត្រង់១ប្រាប់សេក:

-យី.!ស្លាប់ហើយ..ម៉េចក៏ច្រើនម្ល៉េះ?នែ.!ខ្ញុំអត់លុយទេណាំ.!.

កម្លោះសេកញញឹមម្តងទៀតបង្ហាញនូវចិត្តសប្បុរសៈ

-មិនអីទេ ពិសាហើយចាំគិតរឿងហ្នឹង.! .

ណារីញាំផងនឹកគិតផងអំពីកិច្ចការលក់បបររបស់សេក នាងចង់ដឹងថាៈ "ហេតុម៉េចក៏សេកមកអង្គុយលក់ដូចមនុស្សស្រីអញ្ចឹង ឯបងស្រីគេទៅណា?". ប៉ុន្តែគ្មានឱកាសនិងសួរ ទើបខំឆីឱ្យអស់ឆាប់រួចនាងសួរថា :

-ម៉េចថ្លៃប៉ុន្មានដែរមួយចានហ្នឹងបងសេក.? .នាងសួរដើម្បីសងលុយនៅថ្ងៃក្រោយ ។

-មិនបាច់ទេណារី..ខ្ញុំជូនភ្លក្សទាក់ម៉ូយទេតើ.! .គេខំនិយាយលេងបន្លប់ក្តីអៀនអន់ ។

-អរគុណហើយអញ្ចឹង..តែប្រយ័ត្នបងស្រីគាត់ខឹងណាំ.! .

-ទេ..ទេ.!មិនអីទេ.! .គេលើកដៃបដិសេធថាគ្មានបញ្ហាអ្វីទាំងអស់។

សភាពបែបនេះជាហេតុមួយ ធ្វើឱ្យអ្នកកម្លោះសេកនិងនាងក្រមុំណារីបានយល់ចិត្តគ្នាកាន់តែច្រើនថែមទៀត ។

ថ្ងៃជិតត្រង់ តង់ឆ័ត្រធំៗទាំងឡាយដែលគេបាំងកម្តៅព្រះអាទិត្យ





យកម្លប់លក់ដូរអាហារស្រស់ស្រូប ត្រូវបានរើសាទម្លាក់ ជញ្ជូនឥវ៉ាន់អស់ហើយ នៅសល់តែរានរបស់សេកម្នាក់ឯងប៉ុណ្ណោះ ដែលនៅអង្គុយលក់ត្រមង់ជកកមើលឆ្វេងស្តាំញញឹមស្ងួតដាក់អ្នកដំណើរ ដែលដើរទៅមកក្នុងបំណងទាក់ម៉ូយ ប៉ុន្តែអ្នកទាំងនោះពុំបានងាកមើលគេវិញឡើយ។ កម្តៅព្រះអាទិត្យបានបញ្ចេញ ឥទ្ធិពលកាន់តែក្តៅខ្លាំង ហើយមនុស្សម្នាទាំងឡាយក៏ស្ទើរតែស្ងាត់អស់ពីផ្សារដែរ ។ នៅសល់តែកម្មករនិងអ្នកលក់ដូរតាមតូបប៉ុណ្ណោះកំពុងមមាញឹកបំពេញការងារ ។

សេកហៅចនមកជួយរៀបចំរើឥវ៉ាន់មានតុគ្រែជាដើម ឯខ្លួនគេលើកកញ្ជ្រែងចានឆ្នាំងដាក់អម្រែករែកមកផ្ទះ។ ចននៅក្បែរនោះបានចូលទៅជួយរៀបចំជូតសំអាតកន្លែងលក់ដូរ ព្រមទាំងសួរៈ "ម៉េចទៅពូ.!លក់អស់ដែរ?" ។

សេករៀបឥវ៉ាន់ផង គេគ្រវីក្បាលឆ្លើយផង ដោយក្តីព្រួយបារម្ភៈ "មិនអស់ទេ..បានត្រឹមតែរួចដើម.!អើ!ពូទៅមុនហើយចាក់ទឹកលាងកន្លែងផង!" ។

បុរសសេករែកផងនឹកព្រួយខ្លាចបងស្រីបន្ទោសផង ប៉ុន្តែគំនិតមួយបានមករំឭកគេថាៈ"យើងខំលក់ណាស់ដែរ ពុំមែនមានកល់គិតគេចវេះឯណា" ។

ពេលចូលមកដល់ផ្ទះ,សេកឃើញបងស្រីមានទឹកមុខស្រស់ស្រាយ ធ្វើឱ្យក្ដីទុក្ខព្រួយក្នុងគំនិតរបស់គេក៏ផ្ដើមរសាយបាត់ខ្លះទៅដែរ ។

នាងសៀកបានសួររឿងលក់ដូររបស់សេកដោយកិរិយាប្រក្រតី.តែអ្នកកម្លោះប្រែទឹកមុខបន្តិចនិយាយត្អូញត្អែរអំពីបបរនៅសល់ច្រើន ហើយពេលថ្មើរនេះមនុស្សក៏អស់ពីផ្សារទៅហើយផង។ នាងសៀកចូលមកបើកឆ្នាំងមើល ឃើញដូច្នោះនាងមានទឹកមុខប្រែជាសៅហ្មងបន្តិច,សេកបារម្ភណាស់ គេខំទប់អារម្មណ៍កុំឱ្យជ្រួលច្របល់:"ស្លាប់ហើយអ្ហា.!រកស៊ីបើតែយ៉ាងនេះកុំសង្ឃឹម.! ហើយលុយបានប៉ុន្មាន?".នាងបន្ទោសសេក ។

សេកប្រញាប់ស្ទុះទៅទាញកន្ត្រកលុយពីកញ្ច្រែង មកជូនបងស្រី ឆ្លើយប្រាប់ដោយមានអំនួតបន្តិចផង:"នេះចែ.!បានល្មមរួចដើមដែរតើ.!", គេញញឹមលើកទឹកចិត្តឱ្យបងស្រីត្រេកអរតាម ។

នាងសៀកពុំបានបន្ថែមពាក្យសំដីធ្ងន់ធ្ងរបន្ទោសទៀតទេ.នាងប្រើសេកឱ្យរៀបចំដាំបាយ:"អើ..បានរួចខ្លួន.!តើបានអីស៊ី.!ឥឡូវយកទៅទុកដាក់ ហើយប្រញាប់ដាំបាយស៊ី ថ្ងៃត្រង់ហើយ អញមានការទៅនុះមួយភ្លែត!" ។

កម្លោះសេកញញឹម ហើយប្រញាប់ប្រញាល់ធ្វើតាមបង្គាប់. គេជូសបបរចែកក្អួយ២ឆី រួចយកឆ្នាំងទៅត្រាំទឹកនិងផ្ដើមធ្វើអាហារថ្ងៃត្រង់





តម្រូវចិត្តអ្នកផ្ទះ ។

កាលបងស្រីចេញផុតទៅ សេកធ្វើការសាកសួរក្អួយចឹមអំពីរឿងម្ដាយវាទៅទូរស័ព្ទ :

-ក្អួយចឹម.!ចែសៀកទៅទូរស័ព្ទយ៉ាងម៉េចដែរ?,គេញញឹមលោមសួរ ។

-មានអីបានជួបអ៊ុំស្រីហើយ.!" ,ចឹមឆីបបរឆ្លើយអួតប្រាប់សេក។

អ្នកកម្លោះផ្ទុះនូវបីតិភិបពេញដើមទ្រូង រហូតព្រឺរោមព្រឺស្បែក ហើយស្រស់ស្រាយបញ្ឆោកក្អួយចឹម :

-ពិតមែនឬ.?តើគាត់នឹកពួកយើងដែរក្អួយ.?,

-អ៊ូ.! ព្ញម៉ែថាអ៊ុំស្រីនឹកខ្ញុំនឹងម៉ែខ្លាំងណាស់.! ,ចឹមពោលអួតហើយក្រោកដើរកាន់ចានបបរស៊ីក្នុងលក្ខណៈក្មេងរប៉ិលរប៉ូច ។

សេកពុំបានចាប់អារម្មណ៍សកម្មភាពក្អួយទេ គេប្រែជានឹកញញឹមក្នុងចិត្ត ព្រោះមានបងស្រីម្នាក់នៅឯស្រុកក្រៅគ្រាន់បានជាបង្អែកដែរ ។ គេអង្គុយដាំបាយក្បែរចង្ក្រាន យកដៃត្របោមក្បាលជង្គង់ទល់ចង្កាញញឹមគិតថា: "បើចែសោមនៅនឹកស្រឡាញ់ចែសៀកមែន ជីវភាពគាត់និងបានធូរធាច្រើនហើយ",កំពុងតែគិតដូច្នោះ, ស្រាប់តែប្រែទឹកមុខទៅជាស្រងូតជកដង្ហើមធំ"យូរ"ហាក់នឹកស្រណោះខ្លួនក្នុងរឿងអ្វីម្យ៉ាង។ គេបណ្ដោយ

អារម្មណ៍ដែលកំពុងសង្វេគនេះ ឱ្យអណ្តែតទៅតាមតែចិត្តនឹកឃើញរហូត បាយឆ្អិន ទើបជូតទឹកភ្នែកដែលជិតដាមក្នុងរង្វង់ភ្នែកនឹងដៃអាវ ហើយក្រោកទៅលាងចានស្លាបព្រាទុកដាក់ដូចសព្វដង ។

* * *


សូមរង់ចាំអាន

**រឿង**

**នាងបដាចារ -ស្នេហ៍ដូចសុបិន** និង **ព្រះអង្គុលិមាល៍**

ជាស្នាដៃនិពន្ធ **លោក.លុយ សុវណ្ណា** ដែលនឹងចេញផ្សាយឆាប់ៗ បន្ទាប់ពីរឿងប្រាក់ប្រាំដុល្លារនេះទៅ! ។

សៀវភៅ ស្នេហ៍